# مدرسة اهل البيت

صلوات الله عليهم

# សាលា អាស់សុល-បៃត៍

## សៀវភៅសិក្សា គួរអាន (اَلْقُرْآنُ) ថ្នាក់ទី ៣

(អាយុ ៧-៨ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# اَلْقُرْآنُ



ឈ្មោះខ្ញុំ ៖..........................................................................

ឈ្មោះខ្ញុំជាភាសាអារ៉ាប់ ៖

...........................................................................................

# បញ្ជីមាតិកា


មេរៀនទី ១ អារម្ភបទនិងសព្ទបច្ចេកទេស ..... ៥
មេរៀនទី ២ ច្បាប់សម្រាប់អក្សរ ل (ឡាំ) ..... ៩
មេរៀនទី ៣ ច្បាប់សម្រាប់ប្រើ អក្សរ لَا (អាលិហ្វ ឡាំ) ..... ១២
មេរៀនទី ៤ ច្បាប់សម្រាប់ប្រើ អក្សរ لْا (អាលិហ្វ ឡាំ) ..... ១៤
មេរៀនទី ៥ ស៊ូរ៉ោះត៍ អាល់-អ៊ិះខ៍ឡាស្វ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ..... ១៦
មេរៀនទី ៦ នូន គ្វត្វនី (نُون قُطْني) ..... ១៩
មេរៀនទី ៧ ហ៊្វរុហ្វគ ..... ២២
មេរៀនទី ៨ ស៊ូរ៉ោះត៍ អាន់-ណាស់ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ..... ២៤
មេរៀនទី ៩ ស៊ូរ៉ោះត៍ អាន់-ណាស់ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ..... ២៥
មេរៀនទី ១០ សញ្ញាឈប់ (وَقْف) ១ ..... ២៧
មេរៀនទី ១១ សញ្ញាឈប់ (وَقْف) ២ ..... ៣០
មេរៀនទី ១២ ស៊ូរ៉ោះត៍ អាល់-ហ្វាឡាក្វ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ..... ៣៣
មេរៀនទី ១៣ ស៊ូរ៉ោះត៍ អាល់-ហ្វាឡាក្វ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ..... ៣៥
មេរៀនទី ១៤ ហ្វាំស្សាស្វ៍ (ء) ..... ៣៨
មេរៀនទី ១៥ តាអ៊្វ ម៉ារប៊ូត្វោះត៍ (ة - تَاء مَرْبُوطَة) ..... ៤០
មេរៀនទី ១៦ ស៊ូរ៉ោះត៍ អាល់-កាហ្វ៊ីរូន - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ..... ៤២
មេរៀនទី ១៧ ស៊ូរ៉ោះត៍ អាល់-កាហ្វ៊ីរូន - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ..... ៤៤

## មេរៀនទី ១

# អារម្ភបទនិងសព្ទបច្ចេកទេស

### ព្រះមហាគម្ពីរគួរអានគឺអ្វី ?

ព្រះមហាគម្ពីរគួរអានគឺសៀវភៅ ឬ តម្រា ដែលមានចារនូវព្រះរាជបន្ទូល (គឺសម្តី) របស់អល់ឡោះហ៍ﷻ ។

### អ្នកណាតែងព្រះមហាគម្ពីរគួរអានឡើង ?

មិនមានអ្នកណាតែងព្រះគម្ពីរគួរអានឡើងទេ ។ អល់ឡោះហ៍ﷻបានបញ្ជូនពាក្យពេជន៍មកឲ្យព្រះសាស្តាﷺ (ណាប៊ី) តាមរយៈទេវតាឈ្មោះយ៉ិបរ៉អ៊ីលعليه السلام ។

បន្ទាប់មកព្រះសាស្តាﷺបានសូត្រព្រះរាជឱង្ការ (អាយ៉ាត់) ប្រាប់មនុស្ស ។ មនុស្សភាគច្រើនចងចាំព្រះរាជឱង្ការរត់មាត់ តែព្រះសាស្តាﷺបានចាត់តាំងមនុស្សពីរបីនាក់ដើម្បីសរសេរព្រះឱង្ការទុក ។

### ព្រះមហាគម្ពីរគួរអានត្រូវសរសេរជាភាសាអ្វី ?

ព្រះគម្ពីរគួរអានត្រូវសរសេរឡើងជាភាសាអារ៉ាប់ ។ ភាសាអារ៉ាប់សរសេរពីខាងស្តាំមកខាងឆ្វេង ។

### អល់ឡោះហ៍ﷻមានព្រះរាជបន្ទូលថាអ្វីនៅក្នុងព្រះមហាគម្ពីរគួរអាន ?

អល់ឡោះហ៍ﷻរៀបរាប់ប្រាប់នូវរឿងពិតរបស់ព្រះសាស្តានានាعليهم السلام ។

អល់ឡោះហ៍ﷻប្រាប់អំពីទង្វើដែលយើងត្រូវធ្វើ ។

អល់ឡោះហ៍ﷻរៀបរាប់ប្រាប់យើងឲ្យដឹងអំពីឋានសួគ៌និងឋាននរក ។ អល់ឡោះហ៍ﷻរៀបរាប់ប្រាប់យើងច្រើនរឿងណាស់ ។ យើងនឹងយល់រឿងមួយចំនួនពេលយើងធំបន្តិច ។ យើងនឹងយល់រឿងឯទៀតលុះត្រាយើងត្រឡប់ទៅឯ

ព្រះអង្គ عَزَّ وَجَلَّ វិញ ព្រះអង្គ عَزَّ وَجَلَّ នឹងពន្យល់ប្រាប់យើង ។

# ការគោរពព្រះមហាគម្ពីរគួរអាន

យើងត្រូវថែទាំព្រះមហាគម្ពីរគួរអានព្រោះវាជាសៀវភៅពិសេស ។ តើអ្នកត្រូវធ្វើម្តេច ?

យើងត្រូវកាន់ ចាប់ ឬប៉ះព្រះមហាគម្ពីរគួរអានដោយសេចក្តីគោរព (គ្រូត្រូវបង្ហាញសិស្ស) ។

យើងមិនត្រូវបើកព្រះមហាគម្ពីរគួរអានចោលជាដាច់ខាត បើពុំមានអ្នកណាសូត្រទេនោះ ។

យើងមិនត្រូវប៉ះតួអក្សរ (ហ៊្វូរុហ្វ الْحُرُوف) ព្រះមហាគម្ពីរគួរអានទេ បើពុំទាន់បានយកទឹកវូឌុអ៊ុជាមុនសិនទេនោះ ។ គេអាចសូត្រ (ឬអាន) ព្រះមហាគម្ពីរគួរអានបានដោយមិនប៉ះតួអក្សរ ឬដោយដាក់សន្លឹកផ្លាស្ទិចថ្លាទ្រាប់ពីលើសន្លឹកទំព័រព្រះមហាគម្ពីរគួរអាននោះបាន ។

ស៊ូណាត់ (អល់ឡោះហ្វ៍ عَزَّ وَجَلَّ សព្វព្រះហឫទ័យបើព្យាយាមធ្វើ) ពេលសូត្រព្រះមហាគម្ពីរគួរអាន គឺ៖

-គ្របក្បាល - ដោយមួកម្យ៉ាង(កន្តឹប)សម្រាប់ប្រុស ដោយក្រណាត់ទទូរក្បាលសម្រាប់ស្រី ។

-បែរមុខទៅរកគិបឡាត់ពេលគេសូត្រព្រះមហាគម្ពីរគួរអាន ។

យើងសូត្រថា អាអ៊ូស៊្វ ប៊ិលឡាហ៊ិ មីណាស្ស៊ែត៊្តនីរ៉យ៉ីម (أَعُوذُ بِاللَّهِ مِنَ الشَّيْطَانِ الرَّجِيمِ) និងប៊ិសមិលឡាហ៊ិ រ៉ោះហ៊្មាននីរ៉ហ៊ីម (بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ) មុនចាប់ផ្តើមសូត្រព្រះមហាគម្ពីរគួរអាន ។

# សព្ទបច្ចេកទេស

-حَرْفٌ ហារហ្វ៍ (ពហុវចន: حُرُوف ហ៊ូរុហ្វ) - តួអក្សរនៃព្យញ្ជនៈអារ៉ាប់ ។

-نُقْطَة នុក្តោះត៍ (ពហុវចន: نُقَط នូក្កត់) - ចំណុចពីលើឬពីក្រោមហ៊ូរុហ្វ ។

-حَرَكَة ហារ៉កាស់ (ពហុវចន: حَرَكَات ហារ៉កាត់) - សញ្ញាវណ្ណយុត្តសម្រាប់ប្រើផ្សំជាមួយហ៊ូរុហ្វ មាន៖

-ហ្វាត់ហាស់ (الفَتْحَةُ) ـَ

-កាស់រ៉ោះត៍ (الكَسْرَةُ) ـِ

-ដ៉ំម៉ាស់ (الضَمَّةُ) ـُ

-مَخْرَج ម៉ាក់រ៉ជ់ (ពហុវចន: مَخَارِج ម៉ាខ៊ីរីជ) - របៀបថាឲ្យត្រូវតាមសម្លេងហ៊ូរុហ្វ ។

-آيَة អាយ៉ាស់ (ពហុវចន: آيَات អាយ៉ាត់) - ព្រះគាថារបស់គួរអាន ។

-سُورَة ស៊ូរ៉ោះត៍ (ពហុវចន: سُوَر ស៊ូវ៉ារ) - ចំពូកនីមួយនៃចំពូកទាំង ១១៤ របស់គួរអាន ។

# ការអនុវត្ត ១

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

أَعُوذُ بِاللَّهِ مِنَ اَلشَّيْطَانِ اَلرَّجِيمِ

*ខ្ញុំសូមជ្រកកោនក្រោមព្រះជម្រកអល់ឡោះហ្ជ៏ عز وجل ឲ្យចាកផុតមារស្ទៃតន لعنه الله ត្រូវបណ្ដាសា*

២) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

بِسْمِ اَللهِ اَلرَّحْمَٰنِ اَلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ្ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី*

៣) ចូរផាត់ពណ៌រូបក្នុងទំព័រទី ៣ គឺរូបត៌្លិបសូត្រគួរអានខាងលើ ហើយសរសេរឈ្មោះអ្នក (លោក/អ្នកគ្រូសរសេរឈ្មោះសិស្សជាភាសាអារ៉ាប់) ។

៤) ចូរអ្នកយកសន្លឹកផ្លាស្ទិចថ្លាមួយបន្ទះមកអនុវត្តិការប្រើប្រាស់ ។

៥) ចូរកាត់ក្រដាសរឹងមួយបន្ទះតូចទ្រវែង ស្រួចមុខហើយផាត់ពណ៌បន្ទះក្រដាសនោះ ។ ប្រើបន្ទះក្រដាសនេះសម្រាប់សូត្រគួរអានជំនួសចង្អុលដៃ ។

## មេរៀនទី ២

# ច្បាប់សម្រាប់អក្សរ ل (ឡាំ)

ពេលអ្នកជួបពាក្យ اللهَ (អល់ឡោះហ៊ូ ﷻ) ពាក្យ اَللّٰهُمَّ (អល់ឡោះហ៊ូ ﷻ អើយ) នៅក្នុងព្រះគម្ពីរគួរអាន អ្នកត្រូវប្រើច្បាប់នេះ។ ក្នុងករណីខ្លះត្រូវអានអក្សរ ل ដោយមានសម្លេង "ល" ធ្ងន់។ នៅក្នុងករណីឯទៀត ត្រូវអានអក្សរ ل ដោយមានសម្លេង "ល" ស្រាល។

**ពេលដែលត្រូវសូត្រអក្សរ ل នៃពាក្យ الله ដោយមានសម្លេងធ្ងន់**

១. ពេលមានហ្វារុហ្សដាក់ហ្វាត់ហ្ហាស់ឬដ្ហំម៉ាស់ជួបពាក្យ الله។ ឧទាហរណ៍៖

- هُوَ اللّٰهُ អានថា "ហ៊ូវ៉ា អល់**ឡោះ**" (ព្រះអង្គគឺអល់ឡោះហ៊ូ ﷻ)។

- اَمْرُ اللّٰهِ អានាថា "អាំរូ អល់**ឡោះ**" (ព្រះបញ្ជាអល់ឡោះហ៊ូ ﷻ)។

២. ពេលមានហ្វារុហ្សដាក់ស៊ូគូននៅពីមុខហ្វារុហ្សដាក់ដ្ហំម៉ាស់ ជួបពាក្យ الله។ ឧទាហរណ៍៖

- اَنِ اتَّقُوْا اللّٰهَ អានថា "អានីត-តាគុល**ឡោះ**" (ចូរខ្លាចអល់ឡោះហ៊ូ ﷻ)។

៣. ពេលមានហ្វារុហ្សដាក់ស៊ូគូននៅពីមុខហ្វារុហ្សដាក់ហ្វាត់ហ្ហាស់ ជួបពាក្យ الله។

**ពេលដែលត្រូវសូត្រអក្សរ ل នៃពាក្យ الله ដោយមានសម្លេងស្រាល**

១. ពេលមានហ្វារុហ្សដាក់កាស់រ៉ោះត៍ ជួបពាក្យ الله។ ឧទាហរណ៍៖

- بِسْمِ اللّٰهِ អានថា "ប៊ិសមីល**ឡាស់**" (ដោយនូវព្រះនាមអល់ឡោះហ៊ូ ﷻ)។

- قُلِ اللّٰهُمَّ អានាថា "គូលីល**ឡា**ហ៊ុមម៉ា" (ចូរថាអល់ឡោះហ៊ូ ﷻ)។

២. ពេលមានហ្វារុហ្វដាក់ស្វគូននៅពីមុខហ្វារុហ្វដាក់កាស់រ៉ោះត្ល័ ជួបពាក្យ ﷲ ។

៣. ពេលមានហ្វារុហ្វដាក់តាន់វីនជួបពាក្យ ﷲ ។ ឧទាហរណ៍៖

- قَوْمًا اَللّٰهُ អានថា "កៅម៉ាល់**ឡោស់**" (សហគមន៍អល់ឡោះហ៊្វ ﷻ) អានដូច

قَوْمَنِ اللّٰهُ អានថា "កៅម៉ានីល**ឡោស់**" ។

# ការអនុវត្ត ២

១) ចូរអ្នកអានពាក្យខាងក្រោមនេះនិងខំចងចាំន័យរបស់វា ។

១. فَكَفٰى بِا اللّٰهِ អល់ឡោះហ៊្វ ﷻ គ្រប់គ្រាន់[សម្រាប់យើង] ។

២. وَاللّٰهُ يَدْعُوْا អល់ឡោះហ៊្វ ﷻ ហៅពួកអ្នក ។

៣. رَسُوْلُ اَللّٰهِ ព្រះសាសនៈទូតរបស់អល់ឡោះហ៊្វ ﷻ ។

៤. بِاِذْنِ اَللّٰهِ ដោយការអនុញ្ញាតរបស់អល់ឡោះហ៊្វ ﷻ ។

៥. لَآ اِلٰهَ اِلَّا اَللّٰهُ មិនមានព្រះទេក្រៅពីអល់ឡោះហ៊្វ ﷻ ។

៦. لِلّٰهِ ដើម្បីអល់ឡោះហ៊្វ ﷻ ។

២) ចូរសូត្រគួរអាន ។

៣) ចូរធ្វើលំហាត់ ១ ។

# លំហាត់ ១

ចូរផាត់ពណ៌រង្វង់មូលឲ្យត្រឹមត្រូវ ។ ដាក់ពណ៌លឿងពេលហ្ការ៉កាត់នៅពីមុខអក្សរ "ឡាំ" នៃពាក្យ "អល់ឡោះហ្ម៍" ធ្វើឲ្យអក្សរ "ឡាំ" មានសម្លេងស្រាល ។ ដាក់ពណ៌ក្រហមពេលហ្ការ៉កាត់នៅពីមុខអក្សរ "ឡាំ" នៃពាក្យ "អល់ឡោះហ្ម៍" ធ្វើឲ្យអក្សរ "ឡាំ" មានសម្លេងធ្ងន់ ។

| | | |
|---|---|---|
| ـ ـَ اَللّٰه | ـ ـُ اَللّٰه | ـِ ـْ اَللّٰه |
| ـُ ـْ اَللّٰه | ـِ اَللّٰه | ـُ اَللّٰه |

**មេរៀនទី ៣**

# ច្បាប់សម្រាប់ប្រើ اَلْ (អាលិហ្វ ឡាំ)

សព្ទ اَلْ ជានិយតសព្ទប្រាប់សេចក្ដីទៀងទាត់ ។ ដាក់ពីមុខនាមសព្ទណាធ្វើឲ្យនាមសព្ទនោះមានសេចក្ដីទៀងទាត់ឬច្បាស់លាស់ ។ ឧទាហរណ៍ពាក្យ៖

بَيْتٌ ផ្ទះ (នីមួយ) اَلْبَيْتُ ផ្ទះ (ដែលគេស្គាល់) ។

ចូរកត់សម្គាល់ថាពេលដាក់ اَلْ នៅពីមុខនាមសព្ទណា នាមសព្ទនោះចោលតាន់វីនប្រែជាមានហ្ការ៉ាកាត់ខ្លីវិញ ។ ពោលគឺពេល بَيْتٌ ប្រែជា اَلْبَيْتُ - تٌ ទៅជា تُ ។

**-អក្សរចន្ទគតិ** (اَلْحُرُوْفُ الْقَمَرِيَّةُ) - **ច្បាប់សូត្រ** اَلْاِظْهَارُ

បើ اَلْ ជួបពាក្យណាដែលចាប់ផ្ដើមដោយតួអក្សរចន្ទគតិ (اَلْحُرُوْفُ الْقَمَرِيَّةُ) ត្រូវអានអក្សរ "ឡាំ" (ពោលគឺត្រូវបញ្ចេញសម្លេងអក្សរ ل) ។

អក្សរចន្ទគតិ (اَلْحُرُوْفُ الْقَمَرِيَّةُ) មាន ១៤ តួ គឺពាក់កណ្ដាលព្យញ្ជនៈអារ៉ាប់ គឺ៖

ا ب ج ح خ ع غ ف ق ك م و ي ه

# ការអនុវត្ត ៣

១) ចូរអ្នកសូត្រគួរអាន ។

២) ចូរធ្វើលំហាត់ ២ ។

## លំហាត់ ២

ចូរសរសេរហ្វ៊ុរុហ្វ اَلْحُرُوْفُ الْقَمَرِيَّةُ (អក្សរចន្ទគតិ) ទាំងអស់នៅលើរូបលោកខែ ។



## មេរៀនទី ៤

-**អក្សរសុរិយគតិ** (اَلْحُرُوْفُ اَلشَّمْسِيَّةُ) - **ច្បាប់សូត្រ** اَلْاِدْغَامُ

បើ اَلْ ជួបពាក្យណាដែលចាប់ផ្ដើមដោយតួអក្សរសុរិយគតិ (اَلْحُرُوْفُ اَلشَّمْسِيَّةُ) គេមិនអានអក្សរ "ឡាំ" ទេ ។

អក្សរសុរិយគតិ (اَلْحُرُوْفُ اَلشَّمْسِيَّةُ) មាន ១៤ តួ គឺពាក់កណ្ដាលទៀតនៃព្យញ្ជនៈអារ៉ាប់ គឺៈ

ت ث د ذ ر ز س ش ص ض ط ظ ل ن

នៅក្នុងគួរអាន អក្សរចន្ទគតិដែលជួប "ឡាំស្លាប់" (لْ) ជាហ៊្វរុហ្វ មូស្ឋាដ់ដ្ឋាដ់ (គឺដាក់តាស្ឌ់ឌីដ្ឋ) ។

# ការអនុវត្តិ ៤

១) ចូរអ្នកសូត្រគួរអាន ។
២) ចូរធ្វើលំហាត់ ៣ ។

# លំហាត់ ៣

ចូរសរសេរហ៊ូរុហ្វ اَلْحُرُوْفُ الشَّمْسِيَّةُ (អក្សរសុរិយតិ) ទាំងអស់នៅលើរូបថ្ងៃ ។



**មេរៀនទី ៥**

# ស៊ូរ៉ោះត៍ អាល់-អ៊ិះខ្ល៉ាស្វ - ទន្ទេញចាំរត់មាត់ - តាហ្វ៉ៀរ

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

قُلْ هُوَ اللَّهُ أَحَدٌ

*ចូរអ្នកថាៈ "ព្រះអង្គគឺអល់ឡោះហ្ទ៍ ព្រះមួយគត់ ។*

اللَّهُ الصَّمَدُ

*អល់ឡោះហ្ទ៍ ព្រះអនន្តជាទីអាស្រ័យរបស់សព្វសារពើ*

لَمْ يَلِدْ وَلَمْ يُولَدْ

*ព្រះអង្គមិនឲ្យកំណើតទេ ព្រះអង្គមិនត្រូវប្រសូតមកទេ ។*

وَلَمْ يَكُنْ لَهُ كُفُوًا أَحَدٌ

*ពុំមានអ្នកណាដូចព្រះអង្គឡើយ ។"*

# ស៊ូរ៉ោះត៍ អាល់-អ៊ិះខ្ល៉ាស្វ (ជំនឿបរិសុទ្ធ)

ស៊ូរ៉ោះត៍នេះត្រូវដាក់ចុះមកឲ្យព្រះសាស្ដាមូហាំម៉ាដ្ទ ﷺ នៅឯម៉ាក់កាស្វ ដើម្បីឆ្លើយតបពួកយ៉ាហ៊ូឌីដែលសួរអំពីធម្មជាតិអល់ឡោះហ្ទ៍ عز وجل ។

ស៊ូរ៉ោះត៍នេះអធិប្បាយអំពីតៅហ៊ីដ្ទ គឺអំពីការមានអល់ឡោះហ្ទ៍ عز وجل ជាព្រះតែមួយគត់ ។

ព្រះសាស្ដា ﷺ មានព្រះវចនៈថាអ្នកណាសូត្រស៊ូរ៉ោះត៍នេះ អ្នកនោះនឹងបាន

រង្វាន់ស្មើនឹងសូត្រគួរអានមួយភាគបី ។

នៅក្នុងស៊ូរ៉ោះត៍នេះ អល់ឡោះហ្ទ៍﷿ប្រើពាក្យ "អាហាដ៉ុ" ដែលមានន័យថា "មួយគត់" គ្មានពីរ មិនប្រើលេខ "មួយ (វ៉ាហ៊ីដុ)" ទេដែលមានលេខច្រើនទៀតនាំមុខនិងតាមពីក្រោយ ។

នៅក្នុងស៊ូរ៉ោះត៍នេះព្រះអង្គ﷿មានព្រះបន្ទូលថាព្រះអង្គ﷿ជា "អាស្ស៊ូ-ស៊ូម៉ាដ៉ុ" មានន័យថាសព្វសារពើអាស្រ័យព្រះអង្គ﷿ ។ ព្រះអង្គ﷿មិនត្រូវការអ្វីសោះ តែសព្វសត្វលោកនិងសព្វសារពើត្រូវការព្រះអង្គ﷿ ។

នៅក្នុងអាយ៉ាស់ទី ៣ អល់ឡោះហ្ទ៍﷿មានព្រះរាជបន្ទូលថាព្រះអង្គ﷿មិនត្រូវបង្កើតមកទេ ។ ដូច្នេះព្រះអង្គ﷿មិនមានកូនទេ មិនមានឪពុកម្ដាយទេ ។

ហេតុដូច្នេះ អល់ឡោះហ្ទ៍﷿ផ្ទាល់បដិសេធទ្រឹស្ដីរបស់សាសនាគ្រិស្ដដែលថាព្រះអង្គ﷿មានកូននោះ ។

អល់ឡោះហ្ទ៍﷿បញ្ចប់ស៊ូរ៉ោះត៍ ដោយលើកឡើងថាពុំមានអ្នកណាស្មើព្រះអង្គ﷿ទេ ។

ស៊ូរ៉ោះត៍តូចនេះដែលមាន ៤ អាយ៉ាស់ (មិនរាប់ ប៊ិសមិលឡាស់ ទេ) អធិប្បាយសង្ខេបធម្មជាតិពិតរបស់អល់ឡោះហ្ទ៍﷿ ។

បានសេចក្ដីថាអល់ឡោះហ្ទ៍﷿ជាព្រះឯក គ្មានពីរ ក្នុងលក្ខណៈដាច់ខាត ។ ព្រះអង្គ﷿ដាច់ស្រេចពីសព្វសារពើ តែសព្វសារពើអាស្រ័យព្រះអង្គ﷿ (ព្រះអង្គ﷿ជាប្រភពនៃជីវិត) ។ ព្រះអង្គ﷿មិនមានកូនទេ ព្រះអង្គ﷿មិនមានឪពុកម្ដាយទេ ។ ព្រះអង្គ﷿បរិបូរនិងសុក្រឹតឥតខ្ចោះ ដូច្នេះព្រះអង្គ﷿មិនមានអ្វីប្រៀបផ្ទឹម មិនមានអ្វីស្មើឡើយ ។

# ការអនុវត្តិ ៥

១) ចូរអ្នកទន្ទេញស៊ូរ៉ោះត៍ឲ្យត្រូវម៉ាខ្ររីចុនិងស្របតាមច្បាប់សូត្រ ។
២) ចូរធ្វើលំហាត់ ៤ ។

# លំហាត់ ៤

ចូរគូរអ្វីៗដែលអ្នកបានសិក្សាពីស៊ូរ៉ោះត្ត៍ អាល់-អ៊ិះខ្ល៍ឡាស្វ៍ ។

ស៊ូរ៉ោះត្ត៍ អ៊ិះខ្ល៍ឡាស្វ៍

## មេរៀនទី ៦

# នូន គុត្នី (نُونْ قُطْنِي)

ហៅ "នូន គុត្នី" គឺអក្សរកូន "នូន" ដែលជួនកាលនៅចន្លោះពាក្យពីរ មានកាស់រ៉ោះត៍ជានិច្ច ។




តាមទម្លាប់ "នូន គុត្នី" នៅពីក្រោមអក្សរ "អាលិហ្វ" គ្មានហ្ការ៉កាត់ ។ គេអានអក្សរ "នូន" តែមិនអានអក្សរ "អាលិហ្វ" ទេ ។

បើ "នូន គុត្នី" នៅចុងឃ្លា អ្នកសូត្រមានជម្រើសរបៀបសូត្រពីរ គឺៈ

១. បើសូត្រមិនដាក់ គេសូត្រអក្សរ "នូន" តែមិនសូត្រ "អាលិហ្វ" ទេ ។

២. បើសូត្រឈប់ ឃ្លាបន្ទាប់ចាប់ផ្ដើមដោយ "អាលិហ្វ" (ជាមួយ ហ្វាត់ហ្ការស្ញ) ចោល "នូន" ។

# ការអនុវត្តិ ៦

១) ចូរសូត្រពាក្យខាងក្រោមនេះដោយឈប់ ហើយសូត្រកុំឈប់ ។

مُرْتَابٌ ◌ۘ الَّذِينَ (40:34-35) សូត្រមិនឈប់

مُرْتَابٌ ◌ۘ الَّذِينَ (40:34-35) សូត្រឈប់

قَدِيرٌ ◌ۘ الَّذِي (67:1-2) សូត្រមិនឈប់

قَدِيرٌ ◌ۘ الَّذِي (67:1-2) សូត្រឈប់

عَلِيْمُنِ ◌ۙ الَّذِيْ (36:79–80) សូត្រមិនឈប់

عَلِيْمٌ ۙ الَّذِيْ (36:79–80) សូត្រឈប់

عَرْضَانِ ◌ۙ الَّذِينَ (18:100–101) សូត្រមិនឈប់

عَرْضًا ◌ۙ الَّذِينَ (18:100–101) សូត្រឈប់

២) ចូរសូត្រគួរអាន ។

៣) ចូរធ្វើលំហាត់ ៥ ។

# លំហាត់ ៥

ចូរសរសេរហ្សឹរុហ្វពេញរង្វង់ខាងក្រោមនេះ តាមដែលអាចធ្វើបាន ។

សូត្រមិនឈប់

ឈប់ដើម្បីដកដង្ហើម



اِنْ

**មេរៀនទី ៧**

# ហ៊្វូរុហ្វគ

ហ៊្វូរុហ្វ ي و ا គ្មានហ៊ារ៉កាត់ជាហ៊្វូរុហ្វគ (គឺមិនបញ្ចេញសម្លេង) ។

ទោះបីគេសរសេរហ៊្វូរុហ្វទាំងនេះនៅក្នុងគួរអានក៏ដោយ តែមិនត្រូវសូត្រវាទេ ។

ឧទាហរណ៍បែបនេះដែលយើងច្រើនតែឃើញគឺ "អាលិហ្វ" ក្រោយហ៊្វូរុហ្វដាក់ហ្វាត់ហ៊ាស្ទ័តាន់វីន ។

# ការអនុវត្ត ៧

១) ចូរសូត្រពាក្យខាងក្រោមនេះ ចូរគូរវង្វង់មូលហ៊្វូរហ្វគ ហើយចូរព្យាយាមចងចាំន័យពាក្យទាំងនោះ ។

صَلٰوةُ ស្វ៊ឡាតុ៎

بِاسْمِ ក្នុងនាម

تَرٰى គាត់បានឃើញ

وَاعْفُوْا លើកទោសឲ្យ

وَانْصُرْ ជួយ

២) ចូរសូត្រគួរអាន ។

៣) ចូរធ្វើលំហាត់ ៦ ។

# លំហាត់ ៦

ចូរសរសេរនៅក្នុងកន្សោមសម្ដីហ្វូរុហ្វ ي و ا ។

ចូរសរសេរនៅក្នុងកន្សោមសម្ដីខ្វែងជើងក្អែកហ្វូរុហ្វទាំងនេះពេលវាគ ។ ចូរសរសេរនៅក្នុងកន្សោមសម្ដីគូសសញ្ញាក្បៀសហ្វូរុហ្វទាំងនេះ ពេលដែលត្រូវសូត្រវា (គឺពេលវាមានសម្លេង) ។



## មេរៀនទី ៨

# ស៊ូរ៉ោះត៍ អាន់-ណាស់ - ទន្ទេញចាំរត់មាត់ - តាហ្វសៀរ

بِسْمِ ٱللَّهِ ٱلرَّحْمَٰنِ ٱلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

قُلْ أَعُوذُ بِرَبِّ النَّاسِ

*ចូរអ្នកថា៖ "ខ្ញុំសូមពឹងពាក់អាស្រ័យដោយសារព្រះម្ចាស់បណ្ដាមនុស្ស*

مَلِكِ النَّاسِ

*ព្រះមហាក្សត្ររបស់បណ្ដាមនុស្ស*

إِلٰهِ النَّاسِ

*ព្រះរបស់បណ្ដាមនុស្ស*

مِنْ شَرِّ الْوَسْوَاسِ الْخَنَّاسِ

*ឲ្យបានចាកផុតពីអំពើអាក្រក់របស់អ្នកលបខ្សឹបខ្សៀវ*

الَّذِي يُوَسْوِسُ فِي صُدُورِ النَّاسِ

*ដែលខ្សឹបខ្សៀវនៅក្នុងទ្រូងបណ្ដាមនុស្ស*

مِنَ الْجِنَّةِ وَالنَّاسِ

*ក្នុងចំណោមពួកជិន (ពួកអសុរ) និងពួកមនុស្ស ។"*

## មេរៀនទី ៩

# ស៊ូរ៉ោះត៍ អាន់-ណាស់ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ

ស៊ូរ៉ោះត៍នេះជាស៊ូរ៉ោះត៍ចុងក្រោយបង្អស់របស់គួរអាន ។

នៅក្នុងស៊ូរ៉ោះត៍នេះ អល់ឡោះហ្ស៊ﷻថែងអំពីសន្តិសុខរបស់មនុស្សដែលនៅក្បែរព្រះអង្គﷻព្រោះព្រះអង្គﷻជាឥទ្ធិពលកំពូល ជាម្ចាស់របស់មនុស្ស ។

យើងត្រូវការពារខ្លួនពីប្រការអាក្រក់ - គឺការពារខ្លួនពីស្ហៃតន្ﷺ ។

អ្វីដែលយើងត្រូវការពារតទល់នោះ គឺការទាក់ទាញដែលស្ហៃតន្ﷺអាចខ្សឹបខ្សៀវដាក់ក្នុងចិត្តយើងដើម្បីបញ្ចេះយើងឲ្យធ្វើប្រការអាក្រក់ ។

ពួកជិ្ហនជាប្រជានិករដូចប្រជានិករមនុស្សដែរ ។

អាយ៉ាស់ចុងក្រោយ ស្តីអំពីការការពារខ្លួនពីការទាក់ទាញទៅរកបទអាក្រក់របស់ស្ហៃតន្ﷺ ដែលនៅក្នុងចំណោមពួកជិ្ហនឬពួកមនុស្សលោក ។

យើងយល់ច្បាស់ប្រការអាក្រក់ ផ្តុំដោយស្ហៃតន្ﷺនៃសហាគមន៍មនុស្សដែលយើងអាចមើលឃើញនិងស្តាប់ឮ ។ តែយើងមិនអាចយល់ច្បាស់នូវប្រការអាក្រក់ផ្តុំដោយស្ហៃតន្ﷺដែលនៅក្នុងសហាគមន៍ជិ្ហនដែលយើងមិនអាចមើលឃើញ មិនអាចស្តាប់ឮទេ ដែលយើងស្គាល់ស្ទួចស្ទើងណាស់នោះ ។

# ការអនុវត្តិ ៨ និង ៩

១) ចូរអ្នកទន្ទេញឲ្យចាំស៊ូរ៉ោះត៍ឲ្យត្រូវម៉ាខ៉្វរីជ្ហនិងស្របតាមច្បាប់សូត្រ ។

២) ចូរធ្វើលំហាត់ ៧ ។

# លំហាត់ ៧

ចូរគូរអ្វីៗដែលអ្នកបានសិក្សាពីស៊ូរ៉ោះត៊ូ អាន់-ណាស់ ។

ស៊ូរ៉ោះត៊ូ អាន់-ណាស់

## មេរៀនទី ១០

# សញ្ញាឈប់ (وَقْفٌ) ១

វ៉ាក់ហ្វ៍ (وَقْفٌ - ពហុវចនៈ وُقُوْفٌ វូគូហ្វ) ។

ពេលអ្នកសូត្រដល់សញ្ញាឈប់ (ឬដាក់) អ្នកចង់ឈប់កន្លែងនោះឬចង់សម្រាកបន្តិច អ្នកត្រូវគោរពច្បាប់ឬវិន័យខ្លះ គឺ៖

១) បើហ៊្វរុហ្វនៅពីមុខសញ្ញាឈប់នោះមានហ្ការ៉កាត់ ហ្វាត់ហ្កាស្ញុ, កាស់រ៉ោះត្ញ័, ដុំម៉ាស្ញុ, កាស់រ៉ោះត្ញ័-តាន់វីន, ដុំម៉ាស្ញុ-តាន់វីន ត្រូវសូត្រហ្ការ៉កាត់ទាំងនេះដូចស៊ូគូន ។

២) បើហ៊្វរុហ្វនៅពីមុខសញ្ញាឈប់នោះជា ហ្វាត់ហ្កាស្ញុ-តាន់វីន ត្រូវសូត្រហារ៉កាស្ញុនោះដូចហ្វាត់ហ្កាស្ញុ ។

៣) បើហ៊្វរុហ្វនៅពីមុខសញ្ញាឈប់នោះជាអក្សរ ه ឬ អក្សរ ة ត្រូវសូត្រអក្សរនោះដូចមានស៊ូគូន ។

គេសរសេរវូគូហ្វ (សញ្ញាឈប់) ដោយដាក់តួអក្សរនៅលើរង្វង់មូលឬគ្មានតួអក្សរ ឬជាមួយតួអក្សរតូចគ្មានរង្វង់មូល ។

វូគូហ្វ (សញ្ញាឈប់) ជាមួយរង្វង់មូលមាន៖

○ ឈប់ (ឬដាក់) ចប់អាយ៉ាស្ញុ ។

○ۘ ○ۘ ○ۚ ... ○ط ○م ○ق ឈប់ ។ កូន "ត្ញ" ជាពាក្យសង្ខេបរបស់ وَقْفٌ مُطْلَقٌ ។ កូន "មីម" ជាពាក្យសង្ខេបរបស់ وَقْفٌ لَازِمٌ ។ កូន "ក្វហ្វ" ជាពាក្យសង្ខេបរបស់ قِيْلَ عليه الوقف ។

○ۤلا ឈប់ ឬ សូត្របន្ត ។ កូន "សៃ" ជាពាក្យសង្ខេបរបស់ مجوَّز ។

# ការអនុវត្ត ១៣

១) ចូរសូត្រគ្ហួរអាន ។
២) ចូរធ្វើលំហាត់ ១១ ។

## លំហាត់ ១១

ចូរសរសេរហ្ការ៉ាកាស់ដែលត្រូវសូត្រ បើគេឈប់ (ឬដាក់) ។



ចូរសរសេរនៅក្នុងកងមូលទីមួយនូវវគ្គហ្វ (ជាមួយកូនរង្វង់មូល) ទាំងអស់ដែលមានន័យថាត្រូវឈប់ នៅក្នុងកងមូលទីពីរវគ្គហ្វទាំងអស់ដែលមានន័យថាគេអាចឈប់បាន ឬ សូត្របន្តទៀតបាន ។



ចូរផាត់ពណ៌កង "ឈប់" ដោយដាក់ពណ៌ក្រហម កង "ឈប់/បន្ត" ដោយដាក់ពណ៌លឿង ។

**មេរៀនទី ១១**

# សញ្ញាឈប់ (وَقْفْ) ២

គេសរសេរសញ្ញាវគ្គហ្វដោយប្រើរង្វង់មូលដាក់កូនហ្វ៊ុរុហ្វពីលើ ឬគ្មានកូនហ្វ៊ុរុហ្វពីលើ ឬប្រើកូនហ្វ៊ុរុហ្វគ្មានរង្វង់មូល ។

សញ្ញាវគ្គហ្វគ្មានរង្វង់មូល មាន៖

| | |
|---|---|
| م | ត្រូវតែឈប់ ។ |
| ط قف | យកល្អគួរឈប់ ។ |
| ج | អាចឈប់បាន ឬ អាចសូត្របន្តបាន ។ |
| لا | មិនត្រូវឈប់ទេ ។ |
| ق ز صلي صل ص | យកល្អកុំឈប់ ។ |
| وقفه سكته س | ឈប់បន្តិចកុំដកដង្ហើម ។ |
| ∴ ∴ | ឈប់នៅកន្លែងសញ្ញានេះ មួយណាក៏បាន ។ |

# ការអនុវត្ត ១៤

១) ចូរសូត្រគួរអាន ។

២) ចូរធ្វើលំហាត់ ១២ ។

# លំហាត់ ១២

ចូរសរសេរនៅក្នុងកងមូលទីមួយនូវរូវគ្គុហ្វទាំងអស់ (គ្មានរង្វង់មូល) ដែលមានន័យថាត្រូវឈប់ (ហើយផាត់ពណ៌ប្រហមកងនេះ)។ ចូរសរសេរនៅក្នុងកងមូលទីពីរវគ្គុហ្វទាំងអស់ (គ្មានរង្វង់មូល) ដែលមានន័យថាយកល្អគួរឈប់ (ហើយផាត់ពណ៌ទឹកក្រូចកងនេះ)។ ចូរសរសេរនៅក្នុងកងមូលទីបីវគ្គុហ្វទាំងអស់ (គ្មានរង្វង់មូល) ដែលមានន័យថាអាចឈប់បាន អានសូត្របន្តក៏បាន (ហើយផាត់ពណ៌លឿងកងនេះ)។

ត្រូវឈប់ យកល្អគួរឈប់ ឈប់បាន សូត្របន្តបាន

ចូរសរសេរនៅក្នុងកងមូលទីមួយវគ្គុហ្វទាំងអស់ (គ្មានរង្វង់មូល) ដែលមានន័យថាមិនត្រូវឈប់ទេ (ហើយផាត់ពណ៌បៃតងកងនេះ)។ ចូរសរសេរនៅក្នុងកងមូលទីពីរវគ្គុហ្វទាំងអស់ (គ្មានរង្វង់មូល) ដែលមានន័យថាយកល្អមិនគួរឈប់ទេ (ហើយផាត់ពណ៌ផ្ទៃមេឃកងនេះ)

មិនត្រូវឈប់ យកល្អមិនគួរឈប់

## លំហាត់ ១៣ - រៀនសាឡើងវិញសញ្ញាឈប់

ពេលសូត្រគួរអានអ្នកនឹងបានជួបសញ្ញាទាំងនេះ ។ ចូរសរសេរនៅខាងក្រោមនេះនូវសញ្ញាដែលអ្នកបានជួប ហើយចូរសរសេរថាតើត្រូវធ្វើអ្វី ។



**មេរៀនទី ១២**

# ស៊ូរ៉ោះត៏ អាល់-ហ្វាឡាក៏
# ទន្ទេញចាំរត់មាត់ - តាហ្វ់សៀរ

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

قُلْ أَعُوذُ بِرَبِّ الْفَلَقِ ۙ

*ចូរអ្នកថា៖ "ខ្ញុំសូមពឹងពាក់អាស្រ័យដោយសារព្រះម្ចាស់លោហិតារុណ*

مِنْ شَرِّ مَا خَلَقَ ۙ

*ឲ្យបានផុតចាកពីអំពើអាក្រក់បណ្ដាលមកពីអ្វីដែលព្រះអង្គបានបង្កើតមក*

وَمِنْ شَرِّ غَاسِقٍ إِذَا وَقَبَ ۙ

*ឲ្យបានផុតចាកពីអំពើអាក្រក់របស់ភាពងងឹតពេលវាមកដល់*

وَمِنْ شَرِّ النَّفَّاثَاتِ فِي الْعُقَدِ ۙ

*ឲ្យបានផុតចាកពីអំពើអាក្រក់របស់បណ្ដាអ្នកផ្លុំលើចំណង*

وَمِنْ شَرِّ حَاسِدٍ إِذَا حَسَدَ ۚ

*ឲ្យបានផុតចាកពីអំពើអាក្រក់របស់ឥច្ឆាបកគបុគ្គលពេលវាឥច្ឆា ។"*

# ការអនុវត្ត ១៥ & ១៦

១) ចូរទន្ទេញស៊ូរ៉ោះត៏ឲ្យចាំ ត្រូវម៉ាខ៏រីច្ចនិងច្បាប់សូត្រ ។
២) ចូរធ្វើលំហាត់ ១៣ ។

## មេរៀនទី ១៣

# ស៊ូរ៉ោះត៍ អាល់-ហ្វាឡាក់
# ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ

ស៊ូរ៉ោះត៍នេះត្រូវដាក់ចុះមកនៅឯម៉ាក់កាស់ ។

អាល់-ហ្វាឡាក់មានន័យថា "សេតារុណ (គឺពេលថ្ងៃចាប់ផ្តើមរះ)" ។ ស៊ូរ៉ោះត៍នេះស្តីអំពីការសូមជំនួយពីអល់ឡោះហ្ទ៍ﷻ ដើម្បីការពារខ្លួនពីប្រការអាក្រក់នៃមន្តអាគមនិងអំពើអាបធ្មប់ ។

អាយ៉ាស់ ១. ផ្តោតទៅលើការកម្ទេចភាពងងឹតនៃអំពើអាបធ្មប់ ដូចពន្លឺនៃសេតារុណលុបបំបាត់ស្បែងងឹងនៃពេលយប់ ។

អាយ៉ាស់ ២. អល់ឡោះហ្ទ៍ﷻបានបង្កើតសត្វលោកសព្វគ្រប់ ។ សត្វលោកខ្លះគេមើលមិនឃើញទេ សត្វលោកខ្លះគេមើលឃើញ ។ សត្វលោកខ្លះមនុស្សស្គាល់ សត្វលោកខ្លះមនុស្សមិនស្គាល់ទេ ។ យើងសូមជំនួយការពារខ្លួនពីប្រការអាក្រក់ដែលកើតមកពីសត្វលោកអាក្រក់ ។

អាយ៉ាស់ ៣. "ក៏ស៊ីក្វ (غَاسِقٍ)" មានសេចក្តីថាភាពងងឹងនៃការលំបាក (លំបាកកាយក្តី លំបាកចិត្តក្តី) ដែលយើងជួបប្រទះ ។

អាយ៉ាស់ ៤. ការផ្លុំលើចំណងខ្សែជាអំពើអាបធ្មប់មួយបែប ដែលស្រីៗខ្លះធ្វើដើម្បីធ្វើឲ្យអ្នកដទៃឈឺចាប់ ។ ត្រង់នេះយើងសូមជំនួយការពារខ្លួនពីអំពើអាបធ្មប់ ។

អាយ៉ាស់ ៥. ប្រការអាក្រក់ ដែលកើតមកពីការច្រណែនរបស់អ្នកឈ្នានីសគេអាចធ្វើឲ្យមានប្រការអាក្រក់ច្រើនបែប ។ ក្នុងអាយ៉ាស់នេះយើងសូមជំនួយការពារខ្លួនពីប្រការអាក្រក់បែបនេះ ។

ដើម្បីនិយាយសង្ខេបអំពីស៊ូរ៉ោះត៍នេះ យើងសូមជំនួយពីអល់ឡោះហ្ទ៍ﷻឲ្យព្រះអង្គﷻការពារយើងពីប្រការអាក្រក់គ្រប់បែប ដែលអ្នកដទៃព្យាយាមធ្វើមកលើ

ខ្លួនយើង ។

គេត្រូវសូត្រស៊ូរ៉ោះត៍នេះ ពេលគេដឹងខ្លួនថាមានគេមានបំណងអាក្រក់មកលើខ្លួន ។

# លំហាត់ ១៣

ចូរគូរអ្វីៗដែលអ្នកសិក្សាបានពីស៊ូរ៉ោះត្ត៍ អាល់-ហ្វាឡាក់ ។

ស៊ូរ៉ោះត្ត៍ អាល់-ហ្វាឡាក់

**មេរៀនទី ១៤**

# ហាំស្មាស់ (ء)

"ហាំស្មាស់" មានសម្លេងពីរបែបគឺ៖

១) ពេលគេសូត្រ "ហាំស្មាស់ (ء)" ថា "អា" មិនសំខាន់ទេទោះបីវានៅកន្លែងណាក៏ដោយ ឬនៅពីលើអក្សរណាមួយក៏ដោយ (ا و ي) ។

២) ពេលគេសរសេរហាំស្មាស់ដូច ا វាមានសម្លេងថា "អា" បើមិនមានហ្វូរុហ្វឯទៀតនៅពីមុខវាទេ ។

ا គ្រាន់តែដើម្បីឲ្យយើងងាយសូត្រប៉ុណ្ណោះ ។

الْ "អាលិហ្វ" របស់និយតសព្ទប្រាប់សេចក្ដីទៀងទាត់ ។

# ការអនុវត្ត ១៧

១) ចូរសូត្រគួរអាន ។
២) ចូរធ្វើលំហាត់ ១៥ ។

# លំហាត់ ១៤

ចូរសរសេរចម្លើយត្រឹមត្រូវនៅក្នុងរង្វង់បួនជ្រុង ។

១. ء នៅពីលើ ☐ ឬ ☐ ឬ ☐ មានសម្លេងថា ☐ ។

២. ពេលគេសរសេរ ء ដូច ☐ វាមានសម្លេងថា ☐ បើ ☐ វាទេ ។

**មេរៀនទី ១៥**

# តាអ៊ុំ ម៉ារប៊ូតោះតុ៏ (تَاء مَرْبُوطَة - ة)

អក្សរ "តាអ៊ុំ" នេះជាអក្សរ "តាអ៊ុំ" ពិសេស ។

១) វាមានវត្តមាននៅតែចុងពាក្យទេ ។

២) ពាក្យដែលមានអក្សរនេះជាសព្វនាមជានិច្ច ។

៣) ពាក្យដែលមានអក្សរនេះជាសព្វនាមឥត្ថីលិង្គ (គឺពាក្យដែលមានភេទស្រី) ។

៤) គេអានអក្សរ "តាអ៊ុំ" នេះដូចអក្សរ "តាអ៊ុំ" ធម្មតា (ت) លើកលែងតែគេឈប់ (ឬដាក់) ក្រោយពាក្យនោះ ក្នុងករណីនេះត្រូវសូត្រវាដូចអក្សរ "ហ្វាអ៊ុំ (ه)" ។

# ការអនុវត្តិ ១៨

១) ចូរសូត្រគូរអាន ។

២) ចូរធ្វើលំហាត់ ១៥ ។

## លំហាត់ ១៥

ចូរសរសេរប្រការទាំងបួនដែលអ្នកបានសិក្សាអំពីអក្សរ "តាអ៑ ម៉ារប៊ូតោះត៑" នៅលើរូបផ្កាយនីមួយៗខាងក្រោមនេះ ។



## មេរៀនទី ១៦

# ស៊ូរ៉ោះត៊ុ អាល់-កាហ្វីរូន
# ទន្ទេញចាំរត់មាត់ - តាហ្វ់សៀរ

بِسْمِ ٱللَّهِ ٱلرَّحْمَٰنِ ٱلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ្ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

قُلْ يَا أَيُّهَا الْكَافِرُونَ ۙ

*ចូរអ្នកថា៖ "បណ្ដាអ្នកបដិសេធសទ្ធាអើយ !*

لَا أَعْبُدُ مَا تَعْبُدُونَ ۙ

*ខ្ញុំមិនគោរពបូជាអ្វីដែលអស់លោកគោរពបូជានោះទេ*

وَلَا أَنْتُمْ عَابِدُونَ مَا أَعْبُدُ ۚ

*អស់លោកក៏មិនគោរពបូជាព្រះអង្គដែលខ្ញុំគោរពបូជានោះទេដែរ ។*

وَلَا أَنَا عَابِدٌ مَا عَبَدْتُمْ ۙ

*ខ្ញុំមិនមែនអ្នកគោរពបូជាអ្វីដែលអស់លោកគោរពបូជានោះទេ ។*

وَلَا أَنْتُمْ عَابِدُونَ مَا أَعْبُدُ ۗ

*ឯអស់លោកក៏មិនមែនអ្នកគោរពបូជាព្រះអង្គដែលខ្ញុំគោរពបូជានោះទេដែរ ។*

لَكُمْ دِينُكُمْ وَلِيَ دِينِ ۧ

*អស់លោកមានសាសនារបស់អស់លោក ។ ខ្ញុំមានសាសនារបស់ខ្ញុំ ។"*

# ការអនុវត្ត ១៩ & ២០

១) ចូរសូត្រគួរអាន ។

២) ចូរធ្វើលំហាត់ ១៦ ។

## មេរៀនទី ១៧

# ស៊ូរ៉ោះត៊ អាល់-កាហ្វីរូន
# ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ

ស៊ូរ៉ោះត៊នេះត្រូវដាក់ចុះមកនៅឯម៉ាក់កាស់ ជាចម្លើយឆ្លើយតបការស្នើរបស់ពួកមេដឹកនាំគូរ៉យ៉ស្ស៊ (គឺពួកកាហ្វៀរ) ។

ពួកមេដឹកនាំគូរ៉យ៉ស្ស៊បានមកចរចាជាមួយព្រះសាស្តាﷺ ដើម្បីធ្វើកិច្ចព្រមព្រៀងជាមួយព្រះអង្គﷺ ។

ពួកមេដឹកនាំទាំងនោះស្នើសូមឲ្យពួកមិនជឿអល់ឡោះហ៊្ជ និងពួកមុស្លីមគោរពបូជាព្រះរបស់ខ្លួនទៅវិញទៅមកដោយមិនរើសអើង ។

ពួកមេដឹកនាំទាំងនោះបានថា ឲ្យពួកមុស្លីមគោរពបូជាមួយឆ្នាំព្រះដែលពួកគូរ៉យ៉ស្ស៊មិនជឿអល់ឡោះហ៊្ជនោះគោរពបូជា មួយឆ្នាំបន្ទាប់មកឲ្យពួកគូរ៉យ៉ស្ស៊មិនជឿអល់ឡោះហ៊្ជនោះគោរពបូជាព្រះរបស់ពួកមុស្លីម ហើយធ្វើដូច្នេះតរៀងទៅ ។

ការស្នើរបស់ពួកកាហ្វៀរប្រកបដោយការឈ្លាសវៃ ដើម្បីសាកល្បងបង្រាបព្រះសាស្តាﷺ ក្នុងគោលបំណងបំផ្លាញបេសកកម្មព្រះអង្គﷺ ។ ចម្លើយតបពួកគេនៅក្នុងស៊ូរ៉ោះត៊នេះម៉ឺងម៉ាត់និងមិនអាចសម្របសម្រួលតាមតែចិត្តបានទេ ។

គេបានសួរអ៊ីម៉ាំទី ៦ របស់យើង អ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស៊-ស្ស៊ឌិក្ញ صلوات الله عليه والسلام ថាហេតុអ្វីអាយ៉ាស្ស៊តែមួយត្រូវសូត្រសាពីរដង (អាយ៉ាស្ស៊ ៣ និង ៥) ។ ព្រះអង្គ صلوات الله عليه والسلام បានឆ្លើយថាការថាដដែលពីរដងនៅក្នុងស៊ូរ៉ោះត៊នេះ ជាចម្លើយតបការថាពីរដងនៅក្នុងការស្នើរបស់ពួកកាហ្វៀរ ពីព្រោះពួកកាហ្វៀរបានស្នើផ្ទួនឆ្លាស់គ្នា (គោរពព្រះពួកគេមួយឆ្នាំ គោរពព្រះរបស់ពួកមុស្លីមឆ្នាំបន្ទាប់ ឆ្លាស់គ្នា) ។

អាយ៉ាស្ស៊ចុងក្រោយបញ្ជាក់ប្រាប់យើងថា ពុំអាចមានការសម្របសម្រួលរវាងប្រការត្រឹមត្រូវនិងប្រការខុសឆ្គងជាដាច់ខាត និងពុំមានការបង្ខិតបង្ខំឲ្យទៅជា

មុស្លីមទេ ។

អ៊ីមុាំ យ៉ាក្ញ៉ូហ្ងារ អាស្ញ៉ូ-ស្ញ៉ិឌ្ញិក្ញូ صلوات الله عليه والسلام មានវចនៈថាអ្នកណាសូត្រស៊ូរ៉ោះត្ញ៉ូនេះនិង ស៊ូរ៉ោះត្ញ៉ូ អាល់-អ៊ិះខ្ញ៉ុឡាស្ញ៉ូក្នុងស្ញ៉ូឡាត្ញ៉ូប្រចាំថ្ងៃ គេនឹងលើកទោសឲ្យអ្នកនោះនិង ឪពុកម្ដាយអ្នកនោះ ។

# លំហាត់ ១៦

ចូរគូរអ្វីៗដែលអ្នកសិក្សាបានពីស៊ូរ៉ោះត៊ុ អាល់-កាហ្វីរូន ។

ស៊ូរ៉ោះត៊ុ អាល់-កាហ្វីរូន